ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៦៤/២៣ អអរ

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពត"

ព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពត»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ម៉ៅ ធនិន អភិបាល នៃគណៈអភិបាលខេត្តកំពត**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តកំពត**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តកំពត ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តកំពត បែងចែកចេញជា ៨ក្រុង-ស្រុក ៩៣ឃុំ-សង្កាត់ និង៤៩១ភូមិ ដែលមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ៦៩៦.៥៨៣នាក់ សក្តានុពលខេត្តពឹងផ្អែកសំខាន់ទៅលើវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍។ ចំណូលជាមធ្យមប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់គឺ ១.៨១៥ដុល្លារអាមេរិក អត្រាភាពក្រីក្រកាត់បន្ថយត្រឹម ១៤,៨% ទំហំសេដ្ឋកិច្ចខេត្តទាំងមូលមានចំនួន ១.២៨៩លានដុល្លារអាមេរិក ស្មើនឹង ៤,៧% នៃសេដ្ឋកិច្ចជាតិ។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជាបន្តបន្ទាប់ ជូនប្រជាពលរដ្ឋក្រីក្រ គ្រួសារងាយរងហានិភ័យ ស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោម ២ឆ្នាំ និវត្តជន ក៏ដូចជាអតីតយុទ្ធជន ដោយប្រជាពលរដ្ឋបានទទួលការឧបត្ថម្ភសរុបចំនួន ១៧២.១៥៣នាក់ និង ៧៤.៥៩៨គ្រួសារ ចំណាយថវិកាសរុបចំនួន ៤១៧.០៨៩.៧៣៤.០០០រៀល ដែលថវិកាទាំងអស់នោះទទួលបានពីការងារសប្បុរសធម៌ របស់សាខាកាកបាទក្រហមខេត្ត មូលនិធិសមធម៌សុខាភិបាល មូលនិធិជាតិជំនួយសង្គម និងសប្បុរសជន ថ្នាក់ដឹកនាំ មន្ត្រីរាជការខេត្ត ក្រុមការងាររាជរដ្ឋាភិបាល។
- **វិស័យកសិកម្ម៖** ទូទាំងខេត្ត មានផ្ទៃដីបង្កបង្កើនផលចំនួន ១១៥.៥០០ហិកតា ដែលអំណោយផលដល់ដំណាំស្រូវ ម្រេច ធុរេន ដូង ចេកជាដើម។ ទិន្នផលស្រូវទទួលបានជាមធ្យមចំនួន ៤៥៧.១៤២តោន ក្នុងមួយឆ្នាំ ចំណែកដំណាំរួមផ្សំផ្សេងទៀតក៏ទទួលបានទិន្នផលកើនឡើង ដោយរដ្ឋបាលខេត្ត បានរៀបចំចងក្រងជាសហគមន៍ ព្រមទាំងបានបណ្តុះបណ្តាលជំនាញបច្ចេកទេស និងបានជីក និងស្តារប្រព័ន្ធស្រោចស្រពជាប្រចាំ ដូចជា ព្រែក ទំនប់បង្ហៀរទឹក ទ្វាទឹកជាដើម ក្នុងការផ្គត់ផ្គង់ដល់វិស័យកសិកម្ម ក៏ដូចជាបម្រើដល់ប្រជាពលរដ្ឋទូទាំងខេត្ត។ ជាមួយគ្នានេះ ក៏មានសហគមន៍នេសាទ ចំនួន៩ ដែលអាចរកផលបានជាមធ្យម ២១.២៤៥តោន ក្នុងមួយឆ្នាំ មានស្រែអំបិល ដែលក្នុងរយៈពេល ៥ឆ្នាំនេះផលិតបាន ២០២.៥៣០តោន។
- **វិស័យទេសចរណ៍៖** ខេត្តមានរមណីយដ្ឋាន និងគោលដៅទេសចរណ៍ចំនួន ៣៤កន្លែង ដែលតំបន់ទេសចរណ៍ទាំងនោះ បែងចែកចេញជា ៣តំបន់គឺ តំបន់ភ្នំ ទំនាបកណ្តាល និងតំបន់ឆ្នេរ ជាពិសេស គឺមានខ្យល់បរិសុទ្ធ ដែលអាចទាក់ទាញភ្ញៀវទេសចរ ជាក់ស្តែង ក្នុងឆ្នាំ២០២២នេះ ភ្ញៀវទេសចរដែលបានមកលេងកម្សាន្តមានការកើនឡើងចំនួន ៩៥២.៤០០នាក់ បើធៀបនឹងឆ្នាំ២០២១។
- **ការងារសន្តិសុខ សណ្តាប់ធ្នាប់សង្គម៖** រដ្ឋបាលខេត្ត បានសហការជាមួយកងកម្លាំង អាជ្ញាធរគ្រប់ក្រុង-ស្រុក និងមានការចូលរួមពីប្រជាពលរដ្ឋ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ទទួលបានលទ្ធផលល្អប្រសើរ បទល្មើសគ្រប់ប្រភេទមានការថយចុះ ចលនាប្រលងប្រណាំងភូមិ-ឃុំមានសុវត្ថិភាព ទទួលបានជ័យលាភីទាំង ៩៣ឃុំ-សង្កាត់ ក្នុងនោះ ជ័យលាភីលេខ១ ចំនួន ៨២ឃុំ-សង្កាត់។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានខិតខំប្រឹងប្រែងពង្រឹងនូវការអនុវត្តច្បាប់ ក្នុងការបង្កើននូវទំនុកចិត្ត ជានាសុវត្ថិភាព ទាក់ទាញទាំងភ្ញៀវទេសចរ ក៏ដូចជាវិនិយោគិនផងដែរ។ ។

- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** ក្នុងរយៈពេល ៥ឆ្នាំនេះ ទាំងមន្ទីរសាធារណការ និងមន្ទីរអភិវឌ្ឍន៍ជនបទ បានសហការគ្នាក្នុងការកសាងផ្លូវទាំងផ្លូវក្រាលកៅស៊ូ ផ្លូវបេតុង ផ្លូវក្រាលគ្រួសក្រហម និងផ្លូវដី មានប្រវែងសរុប ១.៥១៨,៧២គីឡូម៉ែត្រការរ ស្ពាន៦កន្លែង។ ជាមួយគ្នានេះ ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាតត្រូវបានលើកកម្ពស់ ដោយខេត្តមានស្ថានីយ៍ទឹកស្អាត ចំនួន១៩ ផ្គត់ផ្គង់បាន ៧៣ឃុំ-សង្កាត់ និងបានតបណ្តាញអគ្គិសនីគ្របដណ្តប់បាន ៤៨៨ភូមិ ស្មើនឹង ៩៩,៣៨%។ ដោយឡែក ខេត្តមានកំពង់ផែធំៗ ចំនួន៥ ដោយក្នុងនោះកំពង់ផែទឹកជ្រៅមានជម្រៅទឹក ១៦ម៉ែត្រ អាចអនុញ្ញាតឱ្យនាវាចំណុះ ១៥ ទៅ១៨ម៉ឺនតោន ចូលចតបាន។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានដាក់ចេញនូវទិសដៅការងារសំខាន់ៗ ដើម្បីបន្តអភិវឌ្ឍន៍ខេត្ត ដែលរួមមាន៖

- បន្តរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្ត
- បន្តរៀបចំតំបន់ឆ្នេរសមុទ្រ កែលម្អសួនច្បារ ឆ្នេរតាមដងព្រែក
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធតាមទីប្រជុំជន និងជនបទ
- បន្តដោះស្រាយទំនាស់តាមប្រព័ន្ធតុលាការ និងរៀបចំវេទិកាសាធារណៈ ដើម្បីប្រមូលព័ត៌មានបញ្ហា តម្រូវការ និងស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋ
- បន្តយកចិត្តទុកដាក់រក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ លើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

## IV. សម្គាល់

រដ្ឋបាលខេត្តកំពត បានយកចិត្តទុកដាក់ក្នុងការរៀបចំវេទិកាសាធារជារណៈ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងន័យដោះស្រាយបញ្ហា និងសំណូមពរផ្ទាល់ជូនប្រជាពលរដ្ឋមូលដ្ឋានដោយរដ្ឋបាលខេត្ត បានដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ សម្របសម្រួលដោះស្រាយវិវាទ និងសំណូមពរនានាជូនប្រជាពលរដ្ឋបានចំនួន ១.១៥៨ករណី និងបានរៀបចំវេទិកាសាធារណៈចំនួន ២.៨៧៨លើក ដោះស្រាយបញ្ហាជូនប្រជាំបលរដ្ឋបានចំនួន ៦.៧៩៦ករណីផងដែរ។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត បានប្តេជ្ញាបន្តអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងវេទិកាសាធារណៈនេះជាការងារស្នូល សំដៅលើកកម្ពស់ការរស់នៅរបស់ប្រជាពលរដ្ឋ។ Den

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣